**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ : ១៨៤ ជនស/អសណ

ថ្ងៃ សុក្រ ១៤ រោច ខែ ជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០២៤

**ជម្រាបជូន**

**លោក សុខ វាសនា**

**កម្មវត្ថុ ÷** ករណីសំណើសុំគោលការណ៍សាងសង់អគារពហុមុខងារ កម្ពស់អតិបរមា ៦៦,០០ ម៉ែត្រ មាន ជាន់ក្រោមដី ០១ ជាន់ ជាន់ផ្ទាល់ដី ជាន់ទី ០១ ដល់ជាន់ទី ១៧ មានទីតាំងស្ថិតនៅភូមិ ២ សង្កាត់ ទួលទំពូងទី ១ ខណ្ឌចំការមន រាជធានីភ្នំពេញ

**យោង ÷** - អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

- អនុក្រឹត្យលេខ ២២៤ អនក្រ.បក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់
- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០១១០០២-០០១៣៨ ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០១៨
- ពាក្យស្នើសុំចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០២៤ របស់លោក **សុខ វាសនា**

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឯកភាពជាគោលការណ៍ ចំពោះសំណើសុំខាងលើ។ ម្ចាស់សំណើ ត្រូវរួសរាន់បំពេញបែបបទស្នើសុំលិខិតអនុញ្ញាត សាងសង់ស្របតាមគោលការណ៍ ដូចខាងក្រោម÷

១- សិក្សាផលធៀបក្រឡាផ្ទៃបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍មិនឱ្យលើសពី **៦៥ %** សន្ទស្សន៍ ប្រើប្រាស់ដីមិនឱ្យលើសពី **៥** អគារត្រូវមានសោភណភាពនិងរចនាបថខ្មែរល្អសមស្រប និង មានសុខដុមនីយកម្មទៅនឹងតំបន់ជុំវិញ។

២- រក្សាឆ្លាតម្លាតដូចខាងក្រោម៖

- សំណង់លើដី ត្រូវរក្សាឆ្លាតម្លាតពីព្រំដីផ្នែកជាប់ផ្លូវឱ្យបានស្មើជួរតម្រង់អគារចាស់មានស្រាប់ និងផ្នែកចំហៀងមិនជាប់ផ្លូវឱ្យបានយ៉ាងតិច **២,៥** ម៉ែត្រ។
- សំណង់ក្រោមដី ត្រូវរក្សាឆ្លាតម្លាតពីព្រំដីផ្នែកជាប់ផ្លូវឱ្យបានយ៉ាងតិច **៣,៧០ ម៉ែត្រ** និងផ្នែក ចំហៀងមិនជាប់ផ្លូវឱ្យបានយ៉ាងតិច **២ ម៉ែត្រ**។

៣- ត្រូវរៀបចំសួនជ្រាបទឹកឱ្យបានយ៉ាងតិច ៣០ % នៅលើផ្ទៃដីដែលសល់ពីការសាងសង់ និង ត្រូវរៀបចំដាំដើមឈើឱ្យបានយ៉ាងតិច **១** ដើមលើផ្ទៃដី **១៥០** ម៉ែត្រក្រឡា។

អាសយដ្ឋាន៖ ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 886 999 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

៤- ត្រូវរៀបចំឱ្យមានបរិក្ខារសម្រាប់ជនមានពិការភាព និងចំណតយានយន្តគ្រប់ប្រភេទឱ្យបានត្រឹមត្រូវទៅតាមមុខងារប្រើប្រាស់របស់អគារ និងស្របតាមបទដ្ឋានបច្ចេកទេស។

៥- ត្រូវសិក្សាអាងទឹកក្រោមដីសម្រាប់ពន្លត់អគ្គិភ័យ និងជណ្តើរសុវត្ថិភាពសម្រាប់សង្គ្រោះអគ្គិភ័យស្របតាមបច្ចេកទេស និងមានការយល់ព្រមពីការិយាល័យបង្ការពន្លត់អគ្គិភ័យ នៃស្នងការនគរបាល រាជធានីភ្នំពេញ។

៦- រៀបចំឱ្យមានអាងប្រព្រឹត្តកម្មទឹកកខ្វក់ បំពាក់ម៉ាស៊ីនចម្រោះទឹកកខ្វក់ នៅក្នុងដីឡូត៍ស្នើសុំសាងសង់ និងរៀបចំប្រព័ន្ធលូបង្ហូរទឹកកខ្វក់ឱ្យបានត្រឹមត្រូវតាមបច្ចេកទេស។

៧- ត្រូវបំពេញបែបបទ និងដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ ស្របតាមអនុក្រឹត្យលេខ ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់ និងអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន។

៨- ក្នុងករណីគម្រោងស្នើសុំសាងសង់លើសកម្រិតសន្ទស្សន៍ប្រើប្រាស់ដីអតិបរមាផ្លូវការ ម្ចាស់សំណើត្រូវបង់កម្រៃសេវាតាមការកំណត់របស់រដ្ឋចំពោះផ្ទៃក្រឡាកម្រាលសំណង់ដែលលើសស្របតាមបទបញ្ជា និងនីតិវិធីជាធរមាន។

អាស្រ័យហេតុនេះ សូម **លោក** ជ្រាប និងអនុវត្ត។
សូម **លោក** ទទួលនូវការរាប់អានពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**សាយ សំអាល់**

**ចម្លងជូន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋបាលរាជធានីភ្នំពេញ
- អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម និងអគ្គនាយកដ្ឋានសំណង់
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ខណ្ឌចំការមន
- ឯកសារ កាលប្បវត្តិ